# អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ

រដ្ឋជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ដែលនៅទីនេះហៅថា "អាស៊ាន")៖ ប្រ៊ុយណេ ដារូសាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលនៅទីនេះហៅថា "ភាគី" និងរួមគ្នាហៅថា"ភាគីទាំងនេះ"។

**ទទួលស្គាល់**ថាការជួញដូរមនុស្សជាអំពើរំលោភសិទ្ធិមនុស្សនិងបទល្មើសចំពោះភាពថ្លៃថ្នូររបស់មនុស្ស។

**រម្លឹកឡើងវិញ**ពីគោលបំណង និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍("ធម្មនុញ្ញអាស៊ាន") សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន អនុសញ្ញាសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និងក្នុងករណីពាក់ព័ន្ធ ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ និងកិច្ចព្រមព្រៀងអន្តរជាតិ និងសេចក្តីសម្រេចនានាដទៃទៀតរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស នៅក្នុងការលើកកំពស់ និងកិច្ចការពារសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន ការប្រព្រឹត្តសមរម្យ នីតិរដ្ឋ និងដំណើរការប្រកបដោយការពិនិត្យពិច័យ។

**អះអាងឡើងវិញ**នូវការប្តេជ្ញារបស់យើងចំពោះធម្មនុញ្ញអាស៊ាន ក្នុងន័យឆ្លើយតបយ៉ាងមានប្រសិទ្ធភាព អនុលោមតាមគោលការណ៍ស្តីពីសន្តិសុខពេញលេញ ចំពោះគ្រប់ទម្រង់នៃឧក្រិដ្ឋកម្មនិងការប្រឈមឆ្លងដែន។

**អះអាងឡើងវិញ**ផងដែរនូវការប្តេជ្ញារបស់យើងចំពោះសេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលបានអនុម័តនៅឆ្នាំ ២០០៤ ការឆ្លើយតបយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស៖ ការបញ្ចប់និទណ្ឌភាពសម្រាប់អ្នកជួញដូរមនុស្ស និងការធានាឲ្យមានយុត្តិធម៌សម្រាប់ជនរងគ្រោះឆ្នាំ ២០០៧ ("គោលការណ៍ណែនាំប្រតិបត្តិករអាស៊ាន") សេចក្តីថ្លែងការណ៍រួមនៃមេដឹកនាំអាស៊ាន ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍ ឆ្នាំ ២០១២ និងកិច្ចប្រឹងប្រែងអាស៊ានក្នុងការលើកកំពស់សិទ្ធិមនុស្ស ដែលរួមទាំង សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន ដែលបានអនុម័តឆ្នាំ ២០១២។

**អះអាងឡើងវិញ**បន្ថែមទៀតនូវការប្តេជ្ញារបស់យើងចំពោះកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំ និងមានប្រសិទ្ធភាពជាងមុននៅថ្នាក់តំបន់ និងអន្តរជាតិ ប្រឆាំងការជួញដូរមនុស្ស ក្នុងករណីដែលបទល្មើស

មានលក្ខណៈឆ្លងប្រទេស ដែលរួមទាំង ប៉ុន្តែមិនកំហិតត្រឹម ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង។

**ទទួលស្គាល់**ថា កិច្ចសហប្រតិបត្តិការគឺជាលក្ខខណ្ឌចាំបាច់ដើម្បីឲ្យមានការស៊ើបអង្កេត ការចោទប្រកាន់ និងការលុបបំបាត់ប្រកបដោយជោគជ័យនូវជម្រកសុវត្ថិភាពសម្រាប់ជនល្មើស និងអ្នកសមគំនិតនៅក្នុងការជួញដូរមនុស្ស និងសម្រាប់កិច្ចការពារ និងការផ្តល់ជំនួយឧបត្ថម្ភយ៉ាងមានប្រសិទ្ធភាពដល់ជនរងគ្រោះដោយសារការជួញដូរ។

**ទទួលស្គាល់**ថា ការជួញដូរមនុស្សបង្កឡើងដោយកត្តារួមគ្នាមួយចំនួន ដែលរួមទាំងអំពើពុករលួយក្នុងរដ្ឋាភិបាល ភាពក្រីក្រ អស្ថិរភាពសេដ្ឋកិច្ច ប្រព័ន្ធច្បាប់ដែលគ្មានប្រសិទ្ធភាព ឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងតម្រូវការ ដែលបង្កើនគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលនាំទៅរកការជួញដូរ ដែលត្រូវតែដោះស្រាយឲ្យមានប្រសិទ្ធភាព។

**ដោយដឹង**ថារដ្ឋជាសមាជិកអាស៊ានទាំងអស់ ទោះបីជាប្រទេសប្រភព ឆ្លងកាត់ ឬជាគោលដៅក៏ដោយ មានការទទួលខុសត្រូវរួមគ្នា និងមានគោលដៅរួមដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ចោទប្រកាន់ និងដាក់ទណ្ឌកម្មជនល្មើសជួញដូរមនុស្ស និងការពារ ព្រមទាំងជួយជនរងគ្រោះដោយសារការជួញដូរមនុស្ស។

**ធ្វើការ**គិតគូរពីភាពនៅជិតគ្នា និងព្រំដែនជាប់គ្នានៃរដ្ឋជាសមាជិកអាស៊ាន និងក្នុងស្មារតីតំបន់និយម។

**ដោយដឹង**ពីតម្រូវការដើម្បីបង្កើតលិខិតូបករណ៍ថ្នាក់តំបន់មួយ សម្រាប់ធ្វើការ ជាពិសេសប្រឆាំងការជួញដូរមនុស្ស ដែលជាក្របខ័ណ្ឌច្បាប់សម្រាប់ធ្វើសកម្មភាពនៅថ្នាក់តំបន់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលរួមទាំង កិច្ចការពារ និងការជួយជនរងគ្រោះដោយសារការជួញដូរផងដែរ។

**ទទួលស្គាល់**ពីសារៈសំខាន់នៃវត្តមានលិខិតូបករណ៍ថ្នាក់តំបន់មួយប្រឆាំងការជួញដូរមនុស្ស ដែលជាប់ជាកាតព្វកិច្ចតាមផ្លូវច្បាប់ និងដែលអាចជួយរដ្ឋជាសមាជិកអាស៊ាន ដែលជាប្រទេសប្រភព ប្រទេសឆ្លងកាត់ ឬ ប្រទេសគោលដៅ ដើម្បីដោះស្រាយការប្រឈម អាទិភាព និងយុទ្ធសាស្ត្រខុសៗគ្នានៅថ្នាក់ជាតិ នៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

បានឯកភាពគ្នាដូចតទៅ៖

# ជំពូក ១
# បញ្ញត្តិទូទៅ

## មាត្រា ១
## គោលបំណង

១. លិខិតូបករណ៍ច្បាប់ថ្នាក់តំបន់នេះមានគោលបំណង៖

ក. ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព ជាពិសេស ប្រឆាំងការជួញដូរស្ត្រី និងកុមារ និងធានាឲ្យមានការដាក់ទណ្ឌកម្មបានត្រឹមត្រូវ និងមានប្រសិទ្ធភាពចំពោះអ្នកជួញដូរ។

ខ. ការពារ និងជួយជនរងគ្រោះដោយសារការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព ដោយមានការគោរពយ៉ាងពេញលេញចំពោះសិទ្ធិមនុស្សរបស់ជនរងគ្រោះទាំងនោះ និង

គ. លើកកំពស់កិច្ចសហប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាពក្នុងចំណោមភាគីទាំងនេះ ដើម្បីសម្រេចគោលបំណងទាំងនេះ។

២. ភាគីទាំងនេះឯកភាពថា វិធានការនានាដែលមានចែងក្នុងអនុសញ្ញានេះ ត្រូវតែបានបកស្រាយ និងដាក់ឲ្យអនុវត្តស្របតាមគោលការណ៍នៃការមិនរើសអើង ដែលមានការទទួលស្គាល់ជាអន្តរជាតិ និងនៅថ្នាក់តំបន់ ជាពិសេស ចំពោះជនទាំងឡាយ ដែលពួកគេគឺជាជនរងគ្រោះដោយសារការជួញដូរមនុស្ស។

## មាត្រា ២
## ការប្រើប្រាស់ពាក្យ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

ក. "ការជួញដូរមនុស្ស" សំដៅលើ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងសំចត ឬ ទទួលជននានា តាមមធ្យោបាយនៃការគំរាមកំហែង ឬ ការប្រើប្រាស់កម្លាំង ឬ ទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ជំរិត ការបន្លំ ការបោកបញ្ឆោត ឬ ការប្រើអំណាយរំលោភបំពាន ឬ ការប្រើប្រាស់ស្ថានភាពងាយរងគ្រោះ ឬ ការផ្តល់ ឬ ទទួលកម្រៃ ឬ ផលប្រយោជន៍នានា ដើម្បីសម្រេចបានការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត ក្នុងបំណងកេងប្រវ័ញ្ច ។ ការកេងប្រវ័ញ្ច ត្រូវរាប់បញ្ចូល យ៉ាងហោចណាស់ ការកេងប្រវ័ញ្ចលើពេស្យាកម្មអ្នកដទៃ ឬ ទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើពលកម្ម ឬ សេវាដោយបង្ខំ ទាសភាព ឬ ការប្រព្រឹត្តិប្រហាក់ប្រហែលនឹងទាសភាព សេវាគតិភាព ឬ ការដកហូតសរីរាង្គ។

ខ. ការយល់ព្រមរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ចំពោះការកេងប្រវ័ញ្ចដែលជាការគ្រោងទុកដូចមានចែងក្នុងវាក្យខណ្ឌ(ក)នៃមាត្រានេះ នឹងមិនចាត់ទុកថាបានការឡើយ ក្នុងករណីប្រើប្រាស់មធ្យោបាយណាមួយដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក)។

គ. ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងសំចត ឬ ការទទួលកុមារសម្រាប់គោលដៅនៃការកេងប្រវ័ញ្ចត្រូវបានចាត់ទុកថាជា"ការជួញដូរមនុស្ស" ទោះបីករណីនេះមិនពាក់ព័ន្ធនឹងមធ្យោបាយណាមួយដូចមានចែងក្នុងវាក្យខ័ណ្ឌ(ក)នៃមាត្រានេះក៏ដោយ។

ឃ. "កុមារ" មានន័យថា បុគ្គលណាម្នាក់ដែលមានអាយុតិចជាងដប់ប្រាំបី(១៨)ឆ្នាំ។

ង. "ជនរងគ្រោះ" មានន័យថា រូបវន្តបុគ្គលណាម្នាក់ដែលជាកម្មវត្ថុនៃសកម្មភាពជួញដូរមនុស្ស ដូចមានចែងក្នុងអនុសញ្ញានេះ។

ច. "ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង" មានន័យថា រចនាសម្ព័ន្ធនៃក្រុមណាមួយដែលមានគ្នាបីនាក់ ឬច្រើនជាងនេះ ដែលមានអត្ថិភាពក្នុងអំឡុងពេលណាមួយ និងដែលធ្វើសកម្មភាពស្របគ្នាជាមួយគោលដៅនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ បទល្មើសធ្ងន់ធ្ងរមួយ ឬច្រើន ដូចមានចែងក្នុងអនុសញ្ញានេះ ដើម្បីទទួលបានផលប្រយោជន៍ជាហិរញ្ញវត្ថុ ឬ សម្ភារៈដទៃផ្សេងទៀតដោយផ្ទាល់ ឬ ប្រយោល។

ឆ. "ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" ដូចមានចែងក្នុងវាក្យខណ្ឌ(ច) នៃមាត្រានេះ មានន័យថា ការប្រព្រឹត្តដែលផ្សំដោយបទល្មើសដែលអាចជាប់ទោស តាមរយៈការដកហូតជាអតិបរមានូវសេរីភាព យ៉ាងហោចណាស់អស់រយៈពេលបួនឆ្នាំ ឬ ទណ្ឌកម្មណាមួយធ្ងន់ធ្ងរជាងនេះ។

ជ. "ឧក្រិដ្ឋកម្មឆ្លងដែន" មានន័យថា បទល្មើសដែលមានលក្ខណៈឆ្លងព្រំដែនប្រទេស។ បទល្មើសមួយត្រូវចាត់ទុកថា មានលក្ខណៈឆ្លងដែន ប្រសិនបើ៖

(i) បទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋច្រើនជាងមួយ

(ii) បទល្មើសនោះត្រូវបានប្រព្រឹត្តក្នុងរដ្ឋមួយ ប៉ុន្តែផ្នែកចំបងមួយនៃការរៀបចំ ការគ្រោង ការដឹកនាំ ឬ ការបញ្ជា កើតឡើងនៅក្នុងរដ្ឋមួយផ្សេងទៀត។

(iii)បទល្មើសនោះធ្វើឡើងក្នុងរដ្ឋមួយ ប៉ុន្តែពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ដែលប្រព្រឹត្តសកម្មភាពព្រហ្មទណ្ឌនៅក្នុងរដ្ឋច្រើនជាងមួយ។ ឬ

(iv) បទល្មើសនោះកើតឡើងនៅក្នុងរដ្ឋមួយ ប៉ុន្តែមានឥទ្ធិពលជាច្រើននៅក្នុងរដ្ឋមួយផ្សេងទៀត។

ឈ. "មន្ត្រីសាធារណៈ" មានន័យថា៖

(i) បុគ្គលណាម្នាក់ដែលមានតំណែងក្នុងការិយាល័យនីតិបញ្ញត្តិ ប្រតិបត្តិ រដ្ឋបាល ឬ តុលាការនៃភាគីណាមួយ ទោះបីបានពីការតែងតាំង ឬការបោះឆ្នោត ទោះបីជាតំណែងអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន ទោះបីមានប្រាក់កម្រៃ ឬគ្មាន ដោយមិនគិតពីឋានៈរបស់បុគ្គលនោះឡើយ។

(ii) បុគ្គលណាម្នាក់ដែលអនុវត្តមុខងារសាធារណៈ ដែលរួមទាំង ក្នុងស្ថាប័នសាធារណៈ ឬ សហគ្រាសសាធារណៈ ឬ ផ្តល់សេវាសាធារណៈ ដូចមានចែងក្នុងច្បាប់ជាតិរបស់ភាគីនោះ និងដែលទាក់ទងជាមួយផ្នែកពាក់ព័ន្ធនៃច្បាប់របស់ភាគីនោះ។

ញ. "ទ្រព្យសម្បត្តិ" មានន័យថា ទ្រព្យគ្រប់យ៉ាង ទោះបីជាសាជីវកម្ម ឬ មិនមែនសាជីវកម្ម ចលនទ្រព្យ ឬ អចលនទ្រព្យ រូបិយ៍ ឬ អរូបិយ៍ និងឯកសារ ឬ លិខិតូបករណ៍ច្បាប់ ដែលបង្ហាញពីកម្មសិទ្ធិ ឬ ផលប្រយោជន៍ទាក់ទងនឹងទ្រព្យនោះ។

ដ. "ផលពីឧក្រិដ្ឋកម្ម" មានន័យថា រាល់ទ្រព្យសម្បត្តិ ដែលកើតចេញ ឬ បានមក ដោយផ្ទាល់ ឬ ប្រយោលតាមរយៈការប្រព្រឹត្តបទល្មើសណាមួយ។

ឋ. "ការបង្កក" ឬ "ដកហូត" មានន័យថា ការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្ទេរ ការប្តូរ ការបោះបង់ចោល ឬ ការបញ្ជូនទ្រព្យសម្បត្តិ ឬ ការទទួលគ្រប់គ្រង ឬ ត្រួតត្រាជាបណ្តោះអាសន្នលើទ្រព្យសម្បត្តិ តាមដីកាតុលាការ ឬ ដោយអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។

ឌ. "ការរឹបអូស" ដែលក្នុងករណីសមស្រប អាចរាប់បញ្ចូល ការបាត់បង់សិទ្ធិ មានន័យថា ការរឹបអូសជាអចិន្ត្រៃយ៍នូវទ្រព្យសម្បត្តិ តាមសាលក្រមតុលាការ ឬ ដោយអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។

ឍ. "បទល្មើសដើមចម" មានន័យថា បទល្មើសណាមួយ ដែលផលពីបទល្មើសនោះ អាចក្លាយជាកម្មវត្ថុនៃបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា៧ នៃអនុសញ្ញានេះ។

## មាត្រា ៣
## វិសាលភាពនៃការអនុវត្ត

អនុសញ្ញានេះត្រូវយកទៅអនុវត្តក្នុងការទប់ស្កាត់ ការស៊ើបអង្កេត និងការចោទប្រកាន់បទល្មើសនានា ដូចមានចែងអនុលោមតាមមាត្រា៥ នៃអនុសញ្ញានេះ ក្នុងករណីដែលបទល្មើសទាំងនេះមានលក្ខណៈឆ្លងដែន ដែលរួមទាំងបទល្មើសដែលបានប្រព្រឹត្តដោយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ក៏ដូចជា នៅក្នុងកិច្ចការពារ និងការជួយជនរងគ្រោះដោយសារការជួញដូរមនុស្សផងដែរ។

## មាត្រា ៤
## កិច្ចការពារអធិបតេយ្យភាព

១. ភាគីទាំងនេះត្រូវអនុវត្តកាតព្វកិច្ចនានារបស់ខ្លួននៅក្រោមអនុសញ្ញានេះ ឲ្យស្របជាមួយគោលការណ៍ស្មើភាពគ្នានៃអធិបតេយ្យភាព និងបូរណភាពដែនដីរបស់រដ្ឋនានា និងគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ។

២. អនុសញ្ញានេះពុំផ្តល់សិទ្ធិដល់ភាគីណាមួយនូវយុត្តាធិការ និងការអនុវត្តមុខងាររបស់ខ្លួននៅក្នុងដែនដីរបស់ភាគីដទៃឡើយ ដែលជាសិទ្ធិផ្តាច់មុខរបស់អាជ្ញាធរនៃភាគីដទៃនោះដូចមានចែងក្នុងច្បាប់របស់ភាគីនោះ។

# ជំពូក ២
# ការចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ

## មាត្រា ៥
## ការចាត់ទុកអំពើជួញដូរមនុស្សជាបទល្មើសព្រហ្មទណ្ឌ

១. ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ និងវិធានការដទៃទៀតដែលអាចចាំបាច់ ដើម្បីចាត់ទុកការប្រព្រឹត្តដូចចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ជាបទល្មើសព្រហ្មទណ្ឌ ក្នុងករណីប្រព្រឹត្តដោយចេតនា។

២. ភាគីនីមួយៗក៏ត្រូវអនុម័តផងដែរនូវវិធានការច្បាប់ និងវិធានការដទៃទៀត ដែលអាចចាំបាច់សម្រាប់កំណត់ជាបទល្មើសព្រហ្មទណ្ឌនូវ៖

ក. រាល់ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងវាក្យខណ្ឌ១ នៃមាត្រានេះ អនុលោមតាមគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន។

ខ. ការចូលរួមជាអ្នកសមគំនិតក្នុងបទល្មើសណាមួយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ១នៃមាត្រានេះ។

គ. ការចាត់ចែង ឬ ណែនាំជនដទៃទៀតឲ្យប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងវាក្យខណ្ឌ១ នៃមាត្រានេះ។

៣. ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ ឬ វិធានការដទៃទៀតដែលអាចសមស្រប ដើម្បីកំណត់ឲ្យជនល្មើសជាប់ពិរុទ្ធកម្រិតខ្ពស់ជាងកម្រិតធម្មតា ប្រសិនបើបានរកឃើញមានកត្តាណាមួយដែលបង្កឲ្យស្ថានភាពកាន់តែមានសភាពធ្ងន់ធ្ងរដូចខាងក្រោមនេះ៖

ក. ករណីដែលបទល្មើសនោះពាក់ព័ន្ធជាមួយការបង្ករបួសស្នាមធ្ងន់ធ្ងរ ឬ ការបាត់បង់ជីវិតជនរងគ្រោះ ឬ ជនណាម្នាក់ផ្សេងទៀត ដែលរួមទាំងការបាត់បង់ជីវិតដោយសារតែអត្តឃាដផងដែរ។

ខ. ករណីបទល្មើសនោះកើតឡើងចំពោះជនរងគ្រោះដែលមានស្ថានភាពងាយរងគ្រោះ ដូចជាកុមារ ឬ ជនណាម្នាក់ដែលមិនអាចមើលថែ ឬ ការពារខ្លួនឯងបានពេញលេញ ដោយសារតែពិការភាព ឬ លក្ខខណ្ឌខាងរាងកាយ ឬ ស្មារតី។

គ. ករណីបទល្មើសនោះធ្វើឲ្យជនរងគ្រោះប្រឈមនឹងជំងឺដែលគំរាមកំហែងដល់អាយុជីវិត ដែលរួមទាំង មេរោគអេដស៍/ជំងឺអេដស៍។

ឃ. ករណីបទល្មើសនោះពាក់ព័ន្ធជាមួយជនរងគ្រោះច្រើនជាងម្នាក់។

ង. ករណីឧក្រិដ្ឋកម្មនោះ ត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃសកម្មភាពរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង។

ច. ករណីដែលជនល្មើសធ្លាប់បានជាប់ទោសដោយសារបទល្មើសដូចគ្នា ឬ ប្រហែលគ្នានេះ។

ឆ. ករណីបទល្មើសនោះត្រូវបានប្រព្រឹត្តដោយមន្ត្រីសាធារណៈ នៅក្នុងការអនុវត្តមុខងារសាធារណៈរបស់ខ្លួន។

## មាត្រា ៦

## ការចាត់ទុកការចូលរួមក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ជាបទល្មើសព្រហ្មទណ្ឌ

១. ទាក់ទងនឹងបទល្មើសនានាដែលមានចែងនៅក្នុងអនុសញ្ញានេះ ដូចមានអធិប្បាយក្នុងមាត្រា៣ ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ និងវិធានការផ្សេងទៀត តាមការចាំបាច់ ដើម្បីចាត់ជាបទល្មើសព្រហ្មទណ្ឌ នូវករណីអំពើជួញដូរមនុស្សដែលត្រូវបានប្រព្រឹត្តដោយចេតនា៖

ក. បទល្មើសព្រហ្មទណ្ឌណាមួយ ឬ ទាំងពីរដូចខាងក្រោមនេះ ត្រូវចាត់ទុកថា មានភាពខុសគ្នាពីបទល្មើសដែលជាការប៉ុនប៉ង ឬ ការប្រព្រឹត្តសកម្មភាពព្រហ្មទណ្ឌបានសម្រេច៖

(i) ការឯកភាពជាមួយជនដទៃម្នាក់ ឬច្រើន ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាមួយក្នុងបំណងដែលទាក់ទងដោយផ្ទាល់ ឬ ប្រយោលទៅនឹងការទទួលបានផលប្រយោជន៍ជាប្រាក់កាស ឬ សម្ភារៈដទៃទៀត ក្នុងករណីមានចែងនៅក្នុងច្បាប់ជាតិ ដែលពាក់ព័ន្ធនឹងសកម្មភាពណាមួយដែលបានប្រព្រឹត្តដោយសមាជិកណាម្នាក់ នៅក្នុងការជម្រុញឲ្យមានការព្រមព្រៀង ឬ ការពាក់ព័ន្ធជាមួយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង។

(ii) ការប្រព្រឹត្តដោយបុគ្គលណាម្នាក់ដោយចូលរួមយ៉ាងសកម្មដូចខាងក្រោម ក្នុងករណីបុគ្គលនោះបានដឹងអំពីគោលដៅ និងសកម្មភាពឧក្រិដ្ឋកម្មជាទូទៅរបស់ក្រុមឧក្រិដ្ឋជនដែលមាន

អង្គការចាត់តាំង ឬចេតនានៃសកម្មភាពនេះ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលពាក់ព័ន្ធនោះ ៖

(ក) សកម្មភាពព្រហ្មទណ្ឌរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងនោះ។

(ខ) សកម្មភាពដទៃទៀតរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងនោះ ដោយដឹងថាការចូលរួមរបស់ខ្លួននឹងរួមចំណែកក្នុងការសម្រេចគោលដៅនៃឧក្រិដ្ឋកម្មដូចបានអធិប្បាយខាងលើ។

(ខ) ការចាត់ចែង ដឹកនាំ ជួយ ជម្រុញ សម្រួល ឬ ផ្តល់ការប្រឹក្សាឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលពាក់ព័ន្ធជាមួយក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងណាមួយ។

២. ការយល់ដឹង ចេតនា គោលដៅ គោលបំណង ឬ ការព្រមព្រៀង ដូចមានយោងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះ អាចជាការសន្និដ្ឋានដែលផ្អែកលើអង្គហេតុជាក់ស្តែង។

## មាត្រា ៧
## ការចាត់ទុកការលាងលុយក្រខ្វក់ដែលជាផលបានពីឧក្រិដ្ឋកម្ម ជាបទល្មើសព្រហ្មទណ្ឌ

ទាក់ទងនឹងបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ដូចមានអធិប្បាយក្នុងមាត្រា ៣ ភាគីនីមួយៗត្រូវអនុម័ត អនុលោមតាមគោលការណ៍ជាមូលដ្ឋានគ្រឹះនៃច្បាប់ក្នុងប្រទេសរបស់ខ្លួន នូវវិធានការច្បាប់ និងវិធានការដទៃទៀត ដែលអាចចាំបាច់ដើម្បីចាត់ជាបទល្មើសព្រហ្មទណ្ឌ ក្នុងករណីប្រព្រឹត្តដោយចេតនា៖

ក. (i) ការបំប្លែង ឬ ផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថា ទ្រព្យសម្បត្តិបែបនោះគឺជាផលពីឧក្រិដ្ឋកម្ម ក្នុងបំណងបិទបាំង ឬបំភ្លៃប្រភពដើមល្មើសច្បាប់នៃទ្រព្យសម្បត្តិនោះ ឬ ការជួយបុគ្គលណាម្នាក់ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសដើមចម ដើម្បីគេចចេញពីទណ្ឌកម្មតាមផ្លូវច្បាប់លើសកម្មភាពរបស់ជននោះ។

(ii) ការបិទបាំង ឬបំភ្លៃប្រភេទ ប្រភព ទីតាំង ការចាត់ចែង ការចល័ត ឬ កម្មសិទ្ធិ ឬ សិទ្ធិពិតប្រាកដទាក់ទងនឹងទ្រព្យសម្បត្តិនោះ ដោយដឹងថា ទ្រព្យសម្បត្តិនោះគឺជាផលពីឧក្រិដ្ឋកម្ម។

ខ. ស្របតាមគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន៖

(iii) ការទទួលបាន ការកាន់កាប់ ឬ ប្រើប្រាស់ទ្រព្យសម្បត្តិ ដោយនៅក្នុងពេលទទួល បានដឹងថាទ្រព្យសម្បត្តិនោះគឺជាផលពីឧក្រិដ្ឋកម្ម។

(iv) ការចូលរួម ការពាក់ព័ន្ធជាមួយ ឬ ការសមគំនិតក្នុងការប្រព្រឹត្ត ការប៉ុនប៉ងប្រព្រឹត្ត និងការជួយ ការជម្រុញ ការសម្រួល និងផ្តល់ការប្រឹក្សាសម្រាប់ការប្រព្រឹត្តបទល្មើសបែបនេះណាមួយ ដែលបានកំណត់អនុលោមតាមមាត្រានេះ។

## មាត្រា ៨
## ការចាត់ទុកអំពើពុករលួយ ជាបទល្មើសព្រហ្មទណ្ឌ

១. ទាក់ទងនឹងបទល្មើសនានា ដែលមានចែងក្នុងអនុសញ្ញានេះ ដូចមានអធិប្បាយក្នុងមាត្រា ៣ ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ និងវិធានការផ្សេងទៀត តាមការចាំបាច់ ដើម្បីកំណត់បទល្មើសព្រហ្មទណ្ឌ ក្នុងករណីបានប្រព្រឹត្តដោយចេតនា៖

ក. ការសន្យា ការផ្តល់ជាអំណោយ ការផ្តល់ឲ្យមន្ត្រីសាធារណៈ ដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍មិនសមរម្យ សម្រាប់មន្ត្រីនោះផ្ទាល់ ឬ សម្រាប់បុគ្គល ឬ អង្គភាពណាមួយផ្សេងទៀត ដើម្បីឲ្យមន្ត្រីនោះអនុវត្ត ឬ មិនអនុវត្តចំណាត់ការទៅតាមមុខងារផ្លូវការរបស់ខ្លួន។

ខ. ការបញ្ចុះបញ្ចូល ឬ ការទទួលយកដោយមន្ត្រីសាធារណៈដោយផ្ទាល់ ឬ ប្រយោល នូវផលប្រយោជន៍មិនសមរម្យ សម្រាប់ខ្លួនឯង ឬ សម្រាប់បុគ្គល ឬ អង្គភាពមួយផ្សេង ដើម្បីឲ្យមន្ត្រីនោះអនុវត្ត ឬ មិនអនុវត្តចំណាត់ការទៅតាមមុខងារផ្លូវការរបស់ខ្លួន។

២. ភាគីនីមួយៗត្រូវពិចារណាចាត់ជាបទល្មើសប្រហ្មទណ្ឌនូវទម្រង់ដទៃទៀតនៃអំពើពុករលួយ។

៣. ភាគីនីមួយៗត្រូវអនុម័តវិធានការនានាដែលចាំបាច់ ដើម្បីចាត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការចូលរួមជាអ្នកសមគំនិត នៅក្នុងបទល្មើសណាមួយ ដែលបានកំណត់ អនុលោមតាមមាត្រានេះ។

## មាត្រា ៩
## ការចាត់ទុកការរារាំងយុត្តិធម៌ ជាបទល្មើសព្រហ្មទណ្ឌ

ទាក់ទងនឹងបទល្មើសដែលមានចែងក្នុងអនុសញ្ញានេះ ដូចមានអធិប្បាយក្នុងមាត្រា ៣ ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ និងវិធានការដទៃទៀតតាមការចាំបាច់ ដើម្បីចាត់ជាបទល្មើសព្រហ្មទណ្ឌ ក្នុងករណីមានការប្រព្រឹត្តដោយចេតនា ដូចតទៅ៖

ក. ការប្រើប្រាស់កម្លាំងដោយបង្ខំ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ឬ ការសន្យា ការលើកសំណើ ឬ ការផ្តល់ផលប្រយោជន៍មិនសមរម្យណាមួយ ដើម្បីជម្រុញឲ្យមានការផ្តល់សក្ខីកម្មមិនពិត ឬ រំខាននៅក្នុងការផ្តល់សក្ខីកម្ម ឬ ការផ្តល់ភស្តុតាង នៅក្នុងសវនាការណាមួយ ដែលទាក់ទងនឹងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ។

ខ. ការប្រើប្រាស់កម្លាំងដោយបង្ខំ ការគំរាមកំហែង ឬ ការបំភិតបំភ័យ ដើម្បីរំខានដល់ការអនុវត្តមុខងារផ្លូវការរបស់មន្រ្តីយុត្តិធម៌ ឬ មន្រ្តីអនុវត្តច្បាប់ណាម្នាក់ ដែលទាក់ទងនឹងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ។ គ្មានចំណុចណាមួយក្នុងវាក្យខ័ណ្ឌនេះបំបិទសិទ្ធិរបស់ភាគីនានាពីការអនុម័តច្បាប់ដែលការពារមន្រ្តីសាធារណៈផ្សេងទៀតនោះឡើយ។

## មាត្រា ១០
## យុត្តាធិការ

១. ភាគីនីមួយៗ ត្រូវអនុម័តវិធានការនានាដែលអាចចាំបាច់ ដើម្បីកំណត់យុត្តាធិការរបស់ខ្លួន លើបទល្មើសនានាដូចមានចែង អនុលោមតាមមាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ និងមាត្រា ៩ នៃអនុសញ្ញានេះ ក្នុងករណី៖

ក. បទល្មើសត្រូវបានប្រព្រឹត្តក្នុងដែនដីរបស់ភាគីនោះ ឬ

ខ. បទល្មើសនោះត្រូវបានប្រព្រឹត្តនៅលើនាវាណាមួយដែលប្រើទង់ជាតិរបស់ភាគីនោះ ឬ យន្តហោះណាមួយដែលចុះបញ្ជីនៅក្រោមច្បាប់នៃភាគីនោះ នៅពេលបទល្មើសនោះត្រូវបានប្រព្រឹត្ត។

២. ស្របតាមមាត្រា ៤ នៃអនុសញ្ញានេះ ភាគីណាមួយក៏អាចកំណត់យុត្តាធិការរបស់ខ្លួនសម្រាប់បទល្មើសបែបនេះណាមួយផងដែរ ក្នុងករណីដែល៖

ក. បទល្មើសនោះត្រូវបានប្រព្រឹត្តមកលើជនជាតិរបស់ភាគីនោះ។

ខ. បទល្មើសនោះត្រូវបានប្រព្រឹត្តដោយជនជាតិនៃភាគីនោះ ឬ បុគ្គលគ្មានរដ្ឋ ប៉ុន្តែមានលំនៅស្ថានក្នុងដែនដីរបស់ភាគីនោះ។ ឬ

គ. បទល្មើសនោះ៖

(i) ស្ថិតក្នុងចំណោមបទល្មើសដូចមានចែងក្នុងមាត្រា ៦ វាក្យខ័ណ្ឌ ១ នៃអនុសញ្ញានេះ និងត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃភាគីនោះ ក្នុងគោលដៅបង្កឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយក្នុងដែនដីនៃភាគីនោះ។

(ii) ស្ថិតក្នុងចំណោមបទល្មើសដូចមានចែងក្នុងមាត្រា ៧ វាក្យខ័ណ្ឌ(ខ)(ii) នៃអនុសញ្ញានេះ និងត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃភាគីនោះ ក្នុងគោលដៅបង្កបទល្មើសមួយដូចមានចែងក្នុងមាត្រា ៧ វាក្យខ័ណ្ឌ(ក) (i) ឬ (ii) ឬ (ខ)(i)នៃអនុសញ្ញានេះ នៅក្នុងដែនដីនៃភាគីនោះ។

៣. សម្រាប់គោលបំណងនៃមាត្រា១៩ នៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវអនុម័តវិធានការនានាដែលចាំបាច់ ដើម្បីកំណត់យុត្តាធិការរបស់ខ្លួនលើបទល្មើសនានាដូចមានចែងក្នុងអនុសញ្ញានេះ ក្នុងករណីជនសង្ស័យ មានវត្តមាននៅក្នុងដែនដីរបស់ភាគីនោះ ហើយដែលភាគីនោះមិនបានធ្វើបត្យាប័ន្នបុគ្គលនោះ ដោយសារតែបុគ្គលនោះមានសញ្ជាតិរបស់ភាគីនោះ។

៤. ភាគីនីមួយៗ អាចអនុម័តវិធានការនានាដែលចាំបាច់ ដើម្បីកំណត់យុត្តាធិការរបស់ខ្លួនលើបទល្មើសនានា ដូចមានចែងក្នុងអនុសញ្ញានេះ នៅពេលដែលជនសង្ស័យ មានវត្តមាននៅក្នុងដែនដីរបស់ភាគីនោះ ហើយភាគីនោះមិនធ្វើបត្យាប័ន្នជននោះ។

៥. ប្រសិនបើភាគីមួយអនុវត្តយុត្តាធិការរបស់ខ្លួនដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ ឬ ២ នៃមាត្រានេះ បានទទួលសេចក្តីជូនដំណឹង ឬ ម៉្យាងវិញទៀត បានដឹងថា ភាគីដទៃទៀតមួយ ឬ ច្រើន កំពុងធ្វើការស៊ើបអង្កេត ចោទប្រកាន់ ឬ ដំណើរការនីតិវិធីតុលាការ ដែលទាក់ទងនឹងការប្រព្រឹត្តដូចគ្នានេះ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទាំងនោះ ត្រូវពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមក ទៅតាមករណីសមស្រប ដើម្បីសម្របសម្រួលសកម្មភាពរបស់ខ្លួន។

៦. ដោយមិនប៉ះពាល់ដល់និយាមនៃច្បាប់អន្តរជាតិជាទូទៅ អនុសញ្ញានេះមិនហាមឃាត់ការអនុវត្តយុត្តាធិការព្រហ្មទណ្ឌណាមួយដែលមានចែងដោយភាគីណាមួយ ស្របតាមច្បាប់ក្នុងប្រទេសរបស់ខ្លួនឡើយ ។

# ជំពូក ៣
# ការបង្ការទប់ស្កាត់

## មាត្រា ១១
## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

១. ភាគីទាំងនេះត្រូវរៀបចំគោលនយោបាយ កម្មវិធី និងវិធានការពេញលេញដទៃទៀត៖

ក. ដើម្បីបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង

ខ. ការពារជនរងគ្រោះដោយសារការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ពីការធ្លាក់ខ្លួនជាជនរងគ្រោះឡើងវិញ។

២. ភាគីទាំងនេះត្រូវប្រឹងប្រែងចាត់វិធានការនានា ដូចជា ការស្រាវជ្រាវ យុទ្ធនាការ តាមបណ្តាញព័ត៌មាន និងកិច្ចផ្តួចផ្តើមសង្គម និងសេដ្ឋកិច្ច ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

៣. គោលនយោបាយ កម្មវិធី និងវិធានការដទៃទៀតដែលបានបង្កើតឡើង ស្របតាមមាត្រានេះ ត្រូវរួមបញ្ចូល ទៅតាមករណីសមស្រប នូវកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការពាក់ព័ន្ធដទៃទៀត និងស្ថាប័នដទៃទៀតនៃសង្គមស៊ីវិល។

៤. ភាគីទាំងនេះត្រូវចាត់វិធានការ ឬ ពង្រឹងវិធានការ ដែលរួមទាំង តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីកាត់បន្ថយកត្តានានាដែលធ្វើឲ្យមនុស្ស ជាពិសេស ស្ត្រី និងកុមារងាយរងគ្រោះដោយសារការជួញដូរ ដូចជា ភាពក្រីក្រ ការអភិវឌ្ឍតិចតួច និងខ្វះឱកាសស្មើគ្នា។

៥. ភាគីទាំងនេះត្រូវអនុម័ត ឬ ពង្រឹងវិធានការច្បាប់ និងវិធានការដទៃទៀត ដូចជា ការអប់រំ វិធានការសង្គម ឬ វប្បធម៌ ដែលរួមទាំង តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដើម្បីបញ្ចៀសការលើកទឹកចិត្តឲ្យមានតម្រូវការ ដែលបង្កើនគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលនាំទៅរកការជួញដូរមនុស្ស។

## មាត្រា ១២
## វិស័យនៃកិច្ចសហប្រតិបត្តិការ

អនុលោមតាមច្បាប់ជាតិរបស់ភាគីនីមួយៗ វិស័យនានានៃកិច្ចសហប្រតិបត្តិការនៅក្រោមអនុសញ្ញានេះស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស អាចរាប់បញ្ចូលវិធានការសមស្របនានា ក្នុងចំណោមវិធានការដទៃទៀតដូចតទៅ៖

ក. កាត់បន្ថយតម្រូវការដែលបង្កើនគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលនាំទៅរកការជួញដូរមនុស្ស។

ខ. ចាត់វិធានការ ឬ ពង្រឹងវិធានការដែលសមស្រប ដូចជា តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ឬ ថ្នាក់តំបន់ ដើម្បីទប់ស្កាត់កត្តានានាដែលធ្វើឲ្យមនុស្ស ជាពិសេសស្ត្រី និងកុមារ ងាយរងគ្រោះដោយសារការជួញដូរ ដូចជា ភាពក្រីក្រ ការអភិវឌ្ឍតិចតួច ខ្វះការអប់រំនិងខ្វះឱកាសស្មើគ្នា។

គ. ពង្រឹងគោលនយោបាយ និងកម្មវិធីនានា ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈការស្រាវជ្រាវព័ត៌មាន បង្កើនការយល់ដឹង និងយុទ្ធនាការអប់រំ កិច្ចផ្តួចផ្តើមសង្គម និងសេដ្ឋកិច្ច និងកម្មវិធីបណ្តុះបណ្តាល ជាពិសេស សម្រាប់បុគ្គលនានាដែលងាយរងគ្រោះដោយសារការជួញដូរ។

ឃ. ពង្រឹងបន្ថែមទៀតនូវកិច្ចសហប្របត្តិការថ្នាក់តំបន់លើការស៊ើបអង្កេត និងការចោទប្រកាន់ករណីនៃការជួញដូរមនុស្ស។

ង. បង្កលក្ខណៈឲ្យមានការចល័តរបស់ប្រជាជនដោយស្របច្បាប់ និងធានាឲ្យមានការគោរពលក្ខខណ្ឌអន្តោប្រវេសន៍ ដោយផ្សព្វផ្សាយព័ត៌មានពិតអំពីលក្ខខណ្ឌ និងតម្រូវការដែលជួយដល់ការចូល ចេញ និងការស្នាក់នៅស្របច្បាប់ក្នុងដែនដីនៃភាគីនីមួយៗ។

ច. ផ្លាស់ប្តូរ និងចែករំលែកព័ត៌មានអំពីវិធានការនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារទៅនឹងការជួញដូរមនុស្ស ដើម្បីឲ្យពួកគេអាចធំដឹងក្តី និងរស់នៅក្នុងបរិស្ថានដែលមានសុវត្ថិភាព។

ឆ. លើកកំពស់ការកសាងសមត្ថភាព ដែលរួមទាំង ការបណ្តុះបណ្តាល កិច្ចសហប្រតិបត្តិការបច្ចេកទេស និងចាត់ចែងការប្រជុំសម្របសម្រួលនៅថ្នាក់តំបន់។

ជ. ធានាថា បុគ្គលណាដែលប្រព្រឹត្ត ឬជួយឲ្យមានការជួញដូរមនុស្ស ត្រូវបាននាំមកកាត់ទោស។

### មាត្រា ១៣
### កិច្ចសហប្រតិបត្តិការឆ្លងដែន ការត្រួតពិនិត្យ និងសុពលភាពនៃឯកសារនានា

១. ភាគីនានាត្រូវប្រឹងប្រែងអនុវត្តកិច្ចសហប្រតិបត្តិការឆ្លងដែន ដើម្បីទប់ស្កាត់ និងតាមឃ្លាំមើលការជួញដូរមនុស្ស ទៅតាមករណីសមស្រប ក្នុងចំណោមស្ថាប័នត្រួតពិនិត្យតាមព្រំដែន ដោយៈ

ក. បង្កើត និងរក្សាមធ្យោបាយនៃការប្រាស្រ័យទាក់ទងផ្ទាល់។

ខ. ពង្រឹងការផ្លាស់ប្តូរព័ត៌មានស៊ើបអង្កេត និងការចែករំលែកព័ត៌មាន ដែលរួមទាំង ការរៀបចំ ការបង្កើត និងការប្រើប្រាស់កម្រងទិន្នន័យសមស្រប។

២. ភាគីនានាត្រូវទប់ស្កាត់ចលនានៃអ្នកជួញដូរ និងជនរងគ្រោះដោយសារការជួញដូរ ដោយត្រួតពិនិត្យព្រំដែនឲ្យមានប្រសិទ្ធភាព និងត្រួតពិនិត្យលើការចេញឯកសារអត្តសញ្ញាណ និងឯកសារសម្រាប់ការធ្វើដំណើរ និងតាមរយៈវិធានការដែលមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការបោកប្រាស់ ក្លែងបន្លំ ឬប្រើប្រាស់ឯកសារអត្តសញ្ញាណ និងឯកសារធ្វើដំណើរក្លែងក្លាយ។

## ជំពូក ៤
## កិច្ចការពារ

### មាត្រា ១៤
### កិច្ចការពារជនរងគ្រោះដោយសារការជួញដូរមនុស្ស

១. ភាគីនីមួយៗត្រូវរៀបចំគោលការណែនាំ ឬ នីតិវិធីសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះដោយសារការជួញដូរមនុស្សឲ្យបានត្រឹមត្រូវ និងក្នុងករណីសមស្រប អាចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជួយជនរងគ្រោះ។

២. ក្នុងករណីដែលការជួញដូរមនុស្សកើតឡើងក្នុងប្រទេសច្រើនជាងមួយ ភាគីនីមួយៗត្រូវគោរព និងទទួលស្គាល់អត្តសញ្ញាណជនរងគ្រោះដោយសារការជួញដូរមនុស្ស ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសជាអ្នកទទួល។

៤. ភាគីនីមួយៗត្រូវពិចារណាធ្វើការអនុម័តវិធានការច្បាប់ ឬ វិធានការសមស្របដទៃទៀត ដែលអនុញ្ញាតឲ្យជនរងគ្រោះដោយសារការជួញដូរមនុស្ស ស្ថិតនៅក្នុងដែនដីនៃប្រទេសរបស់ខ្លួនជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ នៅក្នុងករណីសមស្រប។ ភាគីនីមួយៗត្រូវធ្វើការពិចារណាឲ្យបានសមស្របអំពីកត្តាមនុស្សធម៌ និងការអាណិតអាសូរផងដែរ។

៥. ភាគីនីមួយៗត្រូវប្រឹងប្រែងផ្តល់សុវត្ថិភាពរាងកាយដល់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ក្នុងពេលពួកគេស្នាក់នៅក្នុងដែនដីរបស់ភាគីនោះ។

៦. ក្នុងករណីសមស្រប និងទៅតាមកម្រិតដែលអាចធ្វើបាន អនុលោមតាមច្បាប់ជាតិនៃប្រទេសខ្លួន ភាគីនីមួយៗត្រូវការពារភាពឯកជន និងអត្តសញ្ញាណរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ដែលរួមទាំង បង្កើតឲ្យមាននិតិវិធីច្បាប់ដែលទាក់ទងនឹងភាពសម្ងាត់នៃការជួញដូរបែបនោះផងដែរ។

៧. អនុលោមតាមច្បាប់ គោលការណ៍ និងគោលនយោបាយជាតិ និងក្នុងករណីសមស្រប ភាគីនីមួយៗត្រូវពិចារណាចាត់ទុកជនរងគ្រោះដោយសារការជួញដូរមនុស្ស ថាមិនជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬ ខាងរដ្ឋបាលឡើយ ចំពោះសកម្មភាពល្មើសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើសកម្មភាពបែបនោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពនៃការជួញដូរមនុស្ស។

៨. ភាគីនីមួយៗមិនត្រូវឃុំទុកមិនសមហេតុផលនូវជនណាម្នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនថាជាជនរងគ្រោះដោយសារការជួញដូរ នៅក្នុងការឃុំឃាំង ឬ ក្នុងពន្ធនាគារឡើយ នៅមុន នៅក្នុងអំឡុងពេល ឬ ក្រោយពេលមាននីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬ រដ្ឋបាលសម្រាប់អំពើជួញដូរមនុស្ស។

៩. ភាគីនីមួយៗត្រូវប្រាស្រ័យទាក់ទងជាមួយជនដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយសារការជួញដូរមនុស្សនៅក្នុងអំឡុងពេលសមស្រប ជូនព័ត៌មានអំពីប្រភេទនៃកិច្ចការពារ ជួយ និងផ្តល់ការឧបត្ថម្ភដែលជាសិទ្ធិទទួលរបស់ជនរងគ្រោះ អនុលោមតាមច្បាប់ជាតិ និងតាមអនុសញ្ញានេះ។

១០. ក្នុងករណីសមស្រប ភាគីនីមួយៗត្រូវផ្តល់ការថែទាំ និងការឧបត្ថម្ភដល់ជនរងគ្រោះ ក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ អង្គការដទៃទៀត និងស្ថាប័នដទៃទៀតនៃសង្គមស៊ីវិល ដូចតទៅ៖

ក. កន្លែងស្នាក់នៅសមស្រប

ខ. ការប្រឹក្សា និងព័ត៌មាន ជាពិសេស ទាក់ទងនឹងសិទ្ធិស្របច្បាប់របស់ពួកគេ ជាភាសាដែលជនរងគ្រោះដោយសារការជួញដូរអាចយល់បាន។

គ. ជំនួយឧបត្ថម្ភខាងផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងសម្ភារៈនានា និង

ឃ. ឱកាសការងារ ការអប់រំ និងការបណ្តុះបណ្តាល។

១១. ភាគីនីមួយៗត្រូវប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីជួយដល់ការធ្វើសមាហរណកម្មឡើងវិញនូវជនរងគ្រោះដោយសារការជួញដូរ ទៅក្នុងសង្គមនៃភាគីជាអ្នកបញ្ជូន។

១២. ភាគីនីមួយៗត្រូវគិតគូរនៅក្នុងការអនុវត្តតាមចំណុចនានានៅក្នុងមាត្រានេះ ដែលទាក់ទងនឹងអាយុ យេនឌ័រ និងតម្រូវការពិសេស របស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ជាពិសេស តម្រូវការពិសេសរបស់កុមារ។

១៣. ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួន មានវិធានការនានាដែលផ្តល់ឲ្យជនរងគ្រោះដោយសារការជួញដូរ នូវលទ្ធភាពនៃការទទួលបានសំណងចំពោះការខូចខាតដែលកើតមានចំពោះពួកគេ។

១៤. ភាគីនីមួយៗត្រូវថែងអំពីការផ្តល់មូលនិធិសមស្រប ដែលរួមទាំង ក្នុងករណីសមស្រប ត្រូវបង្កើតមូលនិធិជាតិ សម្រាប់ការថែទាំ និងការឧបត្ថម្ភជនរងគ្រោះដោយសារការជួញដូរ។

## មាត្រា ១៥
## ការធ្វើមាតុភូមិនិវត្តន៍ និងការវិលត្រឡប់នៃជនរងគ្រោះ

១. ភាគីនៃសញ្ជាតិរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្ស ឬ ភាគីដែលបានផ្តល់សិទ្ធិរស់នៅជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះនៅពេលចូលក្នុងដែនដីនោះពីដំបូង ត្រូវសម្រួល និងទទួលយកការវិលត្រឡប់នៃជននោះដោយគ្មានការពន្យាពេលមិនសមសហេតុផល ឬ មិនសមរម្យឡើយ ដោយត្រូវគិតគូរពីសុវត្ថិភាពរបស់ជននោះផងដែរ។

២. នៅពេលភាគីមួយចាត់ចែងការវិលត្រឡប់នៃជនរងគ្រោះណាម្នាក់ ស្របតាមវាក្យខ័ណ្ឌ ១ នៃមាត្រានេះ ការវិលត្រឡប់នោះ ត្រូវតែគិតគូរអំពីសុវត្ថិភាពរបស់ជននោះ និងគិតគូរអំពីស្ថានភាពនៅចំពោះមុខនីតិវិធីច្បាប់នានា ដែលទាក់ទងនឹងប្រការដែលថាជននោះគឺជា ជនរងគ្រោះដោយសារការជួញដូរ។

៣. ស្របតាមវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះ និងតាមសំណើរបស់ភាគីជាអ្នកទទួល ភាគីដែលស្នើសុំត្រូវធ្វើការផ្ទៀងផ្ទាត់ដោយគ្មានការពន្យាពេលមិនសមរម្យ និងមិនសមហេតុផល ថាតើជននោះមានសញ្ជាតិរបស់ខ្លួនភាគីនោះ ឬជាអ្នកមានសិទ្ធិរស់នៅអចិន្ត្រៃយ៍ នៅពេលដែលជននោះចូលក្នុងដែនដីនៃភាគីជាអ្នកទទួលដែរឬទេ។

៤. ដើម្បីសម្រួលដល់ការវិលត្រឡប់របស់ជនរងគ្រោះដោយសារការជួញដូរ ដែលគ្មានឯកសារត្រឹមត្រូវ ភាគីនៃសញ្ជាតិរបស់ជនរងគ្រោះនោះ ឬ ភាគីដែលជនរងគ្រោះបានទទួលសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅពេលគាត់ចូលមកក្នុងដែនដីនៃភាគីជាអ្នកទទួលហើយនោះ ត្រូវយល់ព្រមតាមសំណើរបស់ភាគីជាអ្នកទទួល ដើម្បីចេញឯកសារធ្វើដំណើរ ឬ លិខិតអនុញ្ញាតដទៃទៀត ដែលអាចចាំបាច់ ដើម្បីអាចឲ្យជននោះធ្វើដំណើរ និងចូលមកក្នុងដែនដីរបស់ភាគីនោះវិញ។

៥. ភាគីនីមួយៗត្រូវអនុម័តវិធានការច្បាប់ ឬវិធានការដទៃទៀត តាមការចាំបាច់ ដើម្បីបង្កើតឲ្យមានកម្មវិធីមាតុភូមិនិវត្តន៍សមស្រប និងក្នុងករណីចាំបាច់ ត្រូវឲ្យមានការចូលរួមពីស្ថាប័នជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធផងដែរ។

៦. មាត្រានេះពុំមានអនុភាពលើសិទ្ធិណាមួយរបស់ជនរងគ្រោះដោយសារការជួញដូរដែលអាចផ្តល់ឲ្យស្របតាមច្បាប់ក្នុងប្រទេសនៃភាគីជាអ្នកទទួលឡើយ។

៧. មាត្រានេះមិនអានុភាពលើមាត្រានានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី ឬ ពហុភាគីដែលនៅជាធរមាន ឬ ការចាត់ចែងអន្តោប្រវេសន៍ ដែលផ្តល់លក្ខខណ្ឌ និងបុព្វសិទ្ធិសមស្របជាងនេះ ដល់ជនរងគ្រោះដោយសារការជួញដូរនោះឡើយ។

# ជំពូក ៥
# ការពង្រឹងការអនុវត្តច្បាប់

## មាត្រា ១៦
## ការពង្រឹងការអនុវត្តច្បាប់ និងការផ្តន្ទាទោស

១. ភាគីនីមួយៗត្រូវអនុម័តវិធានការនានា ដែលអាចចាំបាច់ ដើម្បីធានាថា អាជ្ញាធរមានសមត្ថកិច្ច ដែលធ្វើការដោះស្រាយបញ្ហានៃការជួញដូរមនុស្ស មានជំនាញ ឬ ចំណេះដឹងសមស្រប សម្រាប់ប្រយុទ្ធប្រឆាំងការ

ជួញដូរមនុស្ស និងការពារជនរងគ្រោះដោយសារការជួញដូរ និងក្នុងករណីសមស្រប ត្រូវបង្កើតអង្គភាពឯកទេស ឬ អាជ្ញាធរសម្រាប់គោលដៅនេះ។

២. ភាគីនីមួយៗត្រូវចាត់វិធានការដែលមានប្រសិទ្ធភាព និងសកម្ម ដើម្បីអង្កេតដាន រារាំង និងដាក់ទោសអំពើពុករលួយ ការលាងលុយកខ្វក់ ការចូលរួមក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង និងការរារាំងយុត្តិធម៌ ដែលជាការរួមចំណែកក្នុងការជួញដូរមនុស្ស។

៣. ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់របស់ខ្លួនមានប្រសិទ្ធភាព ក្នុងការដោះស្រាយករណីនៃការជួញដូរមនុស្ស។

៤. ភាគីនីមួយៗត្រូវអនុម័តវិធានការនានាដែលអាចចាំបាច់ ដើម្បីធានាឲ្យមានការសម្របសម្រួលគោលនយោបាយ និងចំណាត់ការនានារបស់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នសាធារណៈដទៃទៀតប្រឆាំងការជួញដូរមនុស្ស និងក្នុងករណីសមស្រប ត្រូវបង្កើតអង្គភាពសម្របសម្រួល ដើម្បីប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ដូចជា ការជួញដូរមនុស្ស អំពើពុករលួយ ការលាងលុយកខ្វក់ និងការរំខានចំពោះដំណើរការយុត្តិធម៌។

៥. ភាគីនីមួយៗត្រូវចាត់វិធានការស្របតាមច្បាប់ជាតិនៃភាគីជាអ្នកបញ្ជូន និងភាគីជាអ្នកទទួល តាមរយៈកិច្ចសហប្រតិបត្តិការមិនផ្លូវការ ឬ ការជួយគ្នាទៅវិញទៅមកខាងផ្នែកច្បាប់ និងនៅក្នុងករណីសមស្រប ត្រូវលើកទឹកចិត្តដល់ជនរងគ្រោះដោយសារការជួញដូរដើម្បីចូលដោយស្ម័គ្រចិត្ត និងស្នាក់នៅបណ្ដោះអាសន្នក្នុងដែនដីនៃភាគីជាអ្នកទទួល ក្នុងបំណងផ្ដល់សក្ខីកម្ម ឬ ផ្ដល់កិច្ចសហប្រតិបត្តិការក្នុងការផ្ដន្ទាទោសអ្នកជួញដូរពួកគាត់ ដោយត្រូវមានការយកចិត្តទុកដាក់ការពារសុវត្ថិភាពរបស់ជនរងគ្រោះដោយសារការជួញដូរមនុស្សទាំងនោះផងដែរ។

៦. ភាគីនីមួយៗត្រូវផ្ដល់ ឬ ពង្រឹងកម្មវិធីបណ្ដុះបណ្ដាលសម្រាប់មន្ត្រីពាក់ព័ន្ធ ក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដោយផ្ដោតលើវិធីនានាដែលបានប្រើប្រាស់ក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ការស៊ើបអង្កេត និងការចោទផ្ដន្ទាទោសអ្នកជួញដូរមនុស្ស និងការពារសិទ្ធិរបស់ជនរងគ្រោះ ដែលរួមទាំង កិច្ចការពារជនរងគ្រោះ និងគ្រួសាររបស់ពួកគេពីអ្នកជួញដូរមនុស្ស និងភាពឯកជនរបស់ជនរងគ្រោះផងដែរ។

៧. ភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីការពារភាពពេញលេញនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដែលរួមទាំង តាមរយៈកិច្ចការពារជនរងគ្រោះ និងសាក្សី ពីការបំភិតបំភ័យ ការបៀតបៀនទៅតាមការចាំបាច់ និងដាក់ទណ្ឌកម្មជនល្មើសនៅក្នុងសកម្មភាពបំពានបែបនោះឲ្យបានសមស្រប។

៨. ភាគីនីមួយៗត្រូវបង្កើតឲ្យបានសមស្របនៅក្រោមច្បាប់ជាតិរបស់ខ្លួន នូវលក្ខន្តិកៈដែលផ្ដល់សុពលភាពរយៈពេលវែង ដើម្បីការចាប់ផ្ដើមនីតិវិធីសម្រាប់បទល្មើសណាមួយ ដូចមានចែងក្នុងអនុសញ្ញានេះ និងរយៈពេលវែងជាងនេះសម្រាប់ករណីជនសង្ស័យប្រព្រឹត្តបទល្មើស ដែលបានគេចផុតពីសំណាញ់ច្បាប់។

៩. គ្មានប្រការណាមួយនៅក្នុងអនុសញ្ញានេះប៉ះពាល់ដល់គោលការណ៍ដែលទាក់ទងបទល្មើសដូចមានចែងស្របតាមអនុសញ្ញានេះ និងគោលការណ៍នៃកិច្ចការពារស្របច្បាប់ ឬ គោលការណ៍ច្បាប់ដទៃទៀតដែលនៅជាធរមាន និងដែលមានអានុភាពលើភាពស្របច្បាប់នៃការប្រព្រឹត្តដូចដែលមានចែងនៅក្នុងច្បាប់ជាតិនៃភាគីណាមួយឡើយ ហើយដែលបទល្មើសបែបនោះ ត្រូវតែបានចោទប្រកាន់ និងដាក់ទណ្ឌកម្មស្របតាមច្បាប់ជាតិនោះ។

## មាត្រា ១៧
## ការរឹបអូស និងការដកហូត

១. ភាគីនីមួយៗត្រូវអនុម័តវិធានការនានាឲ្យបានម៉ឹងម៉ាត់បំផុតដែលប្រព័ន្ធច្បាប់ជាតិអនុញ្ញាតឲ្យធ្វើបាន ដើម្បីអាចធ្វើការរឹបអូស៖

ក. ផលពីឧក្រិដ្ឋកម្មដែលកើតចេញពីបទល្មើសនានា ដូចមានចែងក្នុងអនុសញ្ញានេះ ឬ ទ្រព្យសម្បត្តិដែលមានតម្លៃស្មើនឹងទំហំនៃផលពីឧក្រិដ្ឋកម្មនោះ។

ខ. ទ្រព្យសម្បត្តិ បរិក្ខារ ឬ សម្ភារៈដទៃទៀតដែលបានប្រើប្រាស់ ឬ ដែលគ្រោងសម្រាប់ប្រើប្រាស់ក្នុងបទល្មើសនានា ដូចមានចែងក្នុងអនុសញ្ញានេះ។

២. ភាគីនីមួយៗត្រូវអនុម័តវិធានការដែលអាចចាំបាច់ ដើម្បីអាចឲ្យមានការកំណត់អត្តសញ្ញាណ ការអង្កេតដាន ការបង្កក ឬ ដកហូតរាល់សម្ភារៈ ដូចមានចែងយោងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះ សម្រាប់គោលដៅនៃការរឹបអូស។

៣. ប្រសិនបើផលពីឧក្រិដ្ឋកម្ម ត្រូវបានបំប្លែង ឬ ផ្លាស់ប្ដូរ មួយផ្នែក ឬ ទាំងស្រុង ទៅជាទ្រព្យដទៃទៀត ទ្រព្យសម្បត្តិបែបនោះនឹងត្រូវជាប់នៅក្រោមវិធានការនានា ដូចមានយោងក្នុងមាត្រានេះជំនួសឲ្យផលពីឧក្រិដ្ឋកម្មនោះ។

៤. ប្រសិនបើផលពីឧក្រិដ្ឋកម្មត្រូវបានលាយបញ្ចូលជាមួយទ្រព្យដែលបានមកតាមវិធីស្របច្បាប់ ទ្រព្យបែបនោះត្រូវតែជាប់ក្នុងលក្ខខណ្ឌនៃការរឹបអូស ក្នុងកម្រិតនៃតម្លៃដែលបានប៉ាន់ប្រមាណនៅក្នុងផលដែលលាយចម្រុះគ្នាបែបនោះ ដោយការអនុវត្តបែបនេះមិនត្រូវប៉ះពាល់ដល់អំណាចនានាដែលទាក់ទងនឹងការបង្កក ឬ ការដកហូតឡើយ។

៥. ផលចំណូល ឬ អត្ថប្រយោជន៍ដទៃទៀតដែលបានពីផលនៃឧក្រិដ្ឋកម្ម ដោយរាប់ចាប់ពីទ្រព្យសម្បត្តិដែលក្នុងនោះមានផ្នែកណាមួយបានពីការបំប្លែង ឬ បានពីការផ្លាស់ប្តូរផលពីឧក្រិដ្ឋកម្ម ឬ ពីទ្រព្យសម្បត្តិដែលក្នុងនោះមានការលាយបញ្ចូលផលពីឧក្រិដ្ឋកម្ម ក៏ត្រូវជាប់នៅក្រោមវិធានការដែលមានយោងក្នុងមាត្រានេះផងដែរ ទៅតាមទម្រង់ដូចគ្នា និងក្នុងកម្រិតដូចគ្នានឹងផលពីឧក្រិដ្ឋកម្មផងដែរ។

៦. សម្រាប់គោលបំណងនៃមាត្រានេះ និងមាត្រា ២១នៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវផ្តល់អំណាចដល់តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតរបស់ខ្លួន ដើម្បីចេញបញ្ជាឲ្យធនាគារផ្តល់របាយការណ៍ហិរញ្ញវត្ថុ ឬ ពាណិជ្ជកម្ម ឬ ធ្វើការដកហូត។ ភាគីនីមួយៗ មិនត្រូវបដិសេធចំណាត់ការដូចមានចែងក្នុងវាក្យខ័ណ្ឌនេះ ដោយសារហេតុផលភាពសម្ងាត់របស់ធនាគារនោះឡើយ។

៧. ភាគីនីមួយៗអាចពិចារណាលទ្ធភាពនៃការតម្រូវឲ្យជនល្មើសបង្ហាញពីប្រភពស្របច្បាប់នៃផលចំណូលដែលស្ថិតក្នុងការសង្ស័យថាកើតចេញពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិដទៃទៀតដែលត្រូវរឹបអូស ក្នុងកម្រិតដែលលក្ខខណ្ឌនោះស្របគ្នាជាមួយគោលការណ៍នៃច្បាប់ និងជាមួយប្រព័ន្ធតុលាការ និងនីតិវិធីដទៃទៀតនៅក្នុងប្រទេស។

៨. ប្រការនានាក្នុងមាត្រានេះនឹងមិនរំលោភលើសិទ្ធិរបស់ភាគីទីបីដែលមានភាពស្មោះត្រង់នោះឡើយ។

៩. គ្មានចំណុចណាមួយក្នុងមាត្រានេះប៉ះពាល់ដល់គោលការណ៍នៃការកំណត់និយមន័យ និងការអនុវត្តវិធានការនានាដែលយោងនៅទីនេះ និងដែលធ្វើឡើងស្របតាមច្បាប់ជាតិរបស់ភាគីណាមួយនោះឡើយ។

# ជំពូក ៦
# កិច្ចសហប្រតិបត្តិការអន្តរជាតិ

## មាត្រា ១៨
## ការជួយគ្នាទៅវិញទៅមកលើផ្នែកច្បាប់នៅក្នុងកិច្ចការព្រហ្មទណ្ឌ

១. ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្សដែលមានលក្ខណៈឆ្លងដែន ភាគីនានាត្រូវចាត់វិធានការជួយគ្នាទៅវិញទៅមកឲ្យបានទូលំទូលាយបំផុតដែលច្បាប់ក្នុងប្រទេសខ្លួនអនុញ្ញាតឲ្យធ្វើបាន លើកិច្ចការច្បាប់នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ ឬ នីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងបទល្មើសនានាដូចបានចែងស្របតាមមាត្រា ៥ នៃអនុសញ្ញានេះ។

២. ភាគីនានាត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមវាក្យខ័ណ្ឌ ១ នៃមាត្រានេះ ស្របតាមសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកលើផ្នែកច្បាប់នៅក្នុងកិច្ចការព្រហ្មទណ្ឌ។

## មាត្រា ១៩

## បត្យាប័ន

១. បទល្មើសនីមួយដែលបានកំណត់ស្របតាមមាត្រា ៥ នៃអនុសញ្ញានេះ ត្រូវចាត់ទុកថាបានបញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័ន នៅក្នុងគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលមានស្រាប់រវាងភាគីនានា។ ភាគីទាំងនេះត្រូវចាត់វិធានការដើម្បីដាក់បញ្ចូលបទល្មើសបែបនោះ ជាបទល្មើសដែលអាចធ្វើបត្យាប័ននៅក្នុងគ្រប់សន្ធិសញ្ញាបត្យាប័នដែលត្រូវធ្វើឡើងរវាងភាគីទាំងនោះ។

២. ប្រសិនបើភាគីណាមួយដាក់លក្ខខណ្ឌលើបត្យាប័នដោយសារតែសន្ធិសញ្ញាណាមួយដែលមានស្រាប់ និងបានទទួលសំណើសុំធ្វើបត្យាប័នពីភាគីមួយផ្សេងទៀត ដែលពុំមានសន្ធិសញ្ញាបត្យាប័ន ភាគីនោះអាចពិចារណាអនុសញ្ញានេះជាមូលដ្ឋានច្បាប់សម្រាប់បត្យាប័នដែលទាក់ទងនឹងរាល់បទល្មើស ដែលបានកំណត់ អនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ។

៣. អនុលោមតាមប្រការនានានៅក្នុងច្បាប់ជាតិ និងសន្ធិសញ្ញាបត្យាប័នរបស់ខ្លួន និងក្នុងករណីដែលបានឃើញថាមានកាលៈទេសៈសមស្រប និងជាករណីបន្ទាន់ និងស្របតាមសំណើរបស់ភាគីស្នើសុំ ភាគីដែលទទួលការស្នើសុំអាចនាំខ្លួនជនដែលស្ថិតក្រោមសំណើបត្យាប័ន និងដែលមានវត្តមាននៅក្នុងដែនដីរបស់ខ្លួនទៅដាក់ក្នុងការឃុំគ្រង ឬ ចាត់វិធានការសមស្របផ្សេងទៀត ដើម្បីធានាវត្តមានរបស់ជននោះសម្រាប់នីតិវិធីបត្យាប័ន។

៤. ក្នុងករណីដែលរកឃើញថា មានជនសង្ស័យនៃបទល្មើសកំពុងស្ថិតនៅក្នុងដែនដីរបស់ភាគីណាមួយ ប្រសិនបើភាគីនោះពុំធ្វើបត្យាប័នជននោះ ស្របតាមបទល្មើសដែលបានកំណត់ ដូចមានចែងក្នុងមាត្រា ៥ នៃអនុសញ្ញានេះ ដោយសារតែជននោះមានសញ្ជាតិរបស់ភាគីនោះ និងតាមសំណើរបស់ភាគីជាអ្នកស្នើសុំធ្វើបត្យាប័ន ភាគីនោះត្រូវជាប់កាតព្វកិច្ចដាក់ជូនករណីនោះ ដោយគ្មានការពន្យាពេលមិនសមរម្យ ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការផ្តន្ទាទោស។ អាជ្ញាធរទាំងនេះត្រូវធ្វើការសម្រេច និងអនុវត្តនីតិវិធីរបស់ខ្លួនតាមរបៀបដូចគ្នានឹងករណីនៃបទល្មើសធ្ងន់ធ្ងរដទៃទៀត ស្របតាមច្បាប់ជាតិរបស់ភាគីនោះ។ ភាគីនានាដែលពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ជាពិសេសលើនីតិវិធី និងការផ្តល់ភស្តុតាង ដើម្បីធានាប្រសិទ្ធភាពនៃការផ្តន្ទាទោសនោះ។

៥. សម្រាប់គោលបំណងនៃមាត្រានេះ ភាគីនីមួយៗត្រូវតែងតាំងអាជ្ញាធរថ្នាក់កណ្តាលមួយសម្រាប់ទទួលសេចក្តីជូនដំណឹងអំពីការតំកល់លិខិតូបករណ៍អនុសញ្ញានេះ។

## មាត្រា ២០
## កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់

១. ភាគីនានាត្រូវធ្វើសហប្រតិបត្តិការជិតស្និទ្ធជាមួយគ្នា ស្របតាមប្រព័ន្ធច្បាប់ និងប្រព័ន្ធរដ្ឋបាលនៅក្នុងប្រទេសរៀងៗខ្លួន ដើម្បីពង្រឹងប្រសិទ្ធភាពនៃសកម្មភាពអនុវត្ត ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ។ ភាគីនីមួយៗត្រូវអនុម័តវិធានការឲ្យមានប្រសិទ្ធភាព៖

ក. ដើម្បីពង្រឹង និងក្នុងករណីចាំបាច់ បង្កើត ក៏ដូចជា ប្រើប្រាស់មធ្យោបាយដែលមានស្រាប់ សម្រាប់ការប្រាស្រ័យទាក់ទងរវាងអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័ន និងការិយាល័យនានារបស់ខ្លួន ដើម្បីសម្រួលដល់ការផ្លាស់ប្តូរដោយសុវត្ថិភាព និងឆាប់រហ័សនូវព័ត៌មាន ដែលទាក់ទងនឹងគ្រប់ទិដ្ឋភាពនៃបទល្មើស ដូចមានចែងក្នុងអនុសញ្ញានេះ ដែលរួមទាំង ចំណងទាក់ទងជាមួយសកម្មភាពព្រហ្មទណ្ឌផ្សេងទៀតផងដែរ ក្នុងករណីដែលភាគីពាក់ព័ន្ធទាំងនេះយល់ថាសមស្រប។

ខ. ដើម្បីធ្វើសហប្រតិបត្តិការជាមួយភាគីដទៃទៀត ក្នុងការស៊ើបអង្កេតដែលទាក់ទងនឹងបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ ដែលទាក់ទងនឹង៖

(i) អត្តសញ្ញាណ ទីកន្លែង និងសកម្មភាពរបស់ជនសង្ស័យថាបានពាក់ព័ន្ធនៅក្នុងបទល្មើសបែបនោះ ឬ ទីកន្លែងរបស់ជនពាក់ព័ន្ធដទៃទៀត។

(ii) ការចល័តផលពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិដែលកើតចេញពីការប្រព្រឹត្តបទល្មើសនោះ។

(iii) ការចល័តទ្រព្យសម្បត្តិ បរិក្ខារ ឬ សម្ភារៈដទៃទៀតដែលបានប្រើប្រាស់ ឬ សម្រាប់ប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសបែបនោះ។

គ. ដើម្បីផ្តល់មធ្យោបាយចាំបាច់ ឬ វត្ថុតាងគ្រប់គ្រាន់ទៅតាមករណីសមស្រប សម្រាប់ការវិភាគ និងការស៊ើបអង្កេត។

ឃ. ដើម្បីសម្រួលឲ្យមានការសម្របសម្រួលដោយប្រសិទ្ធភាព រវាងអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័ន និងការិយាល័យនានារបស់ខ្លួន និងដើម្បីលើកកំពស់ការផ្លោះប្តូរមន្ត្រី និងអ្នកជំនាញការផ្សេងទៀត ដែលរួមទាំង អនុលោមតាមកិច្ចព្រមព្រៀងទ្វេភាគី ឬ ការចាត់ចែងនានា រវាងភាគីដែលពាក់ព័ន្ធ សម្រាប់ការដាក់ឲ្យមានមន្ត្រីទំនាក់ទំនងប្រចាំការ។

ង. ដើម្បីផ្លាស់ប្តូរព័ត៌មានជាមួយភាគីដទៃទៀតអំពីមធ្យោបាយ និងវិធីជាក់លាក់ ដែលអ្នកជួញដូរបានប្រើប្រាស់ ដែលរួមទាំង ផ្លូវ និងច្រករបៀង ព្រមទាំង ការប្រើប្រាស់អត្តសញ្ញាណ ឯកសារក្លែងក្លាយ ឬ បន្លំ ឬ មធ្យោបាយផ្សេងទៀតនៃការបិទបាំងសកម្មភាពរបស់ពួកគេផងដែរ។

ច. ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលវិធានការរដ្ឋបាល និងវិធានការដទៃទៀត ដែលសមស្រប សម្រាប់ការកំណត់អត្តសញ្ញាណពីដើមដំបូង នូវបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ។

២. ក្នុងគោលដៅផ្តល់សុពលភាពដល់អនុសញ្ញានេះ ភាគីនានាត្រូវពិចារណាការចុះកិច្ចព្រមព្រៀង ឬ ការចាត់ចែងជាលក្ខណៈទ្វេ ឬ ពហុភាគី នូវកិច្ចសហប្រតិបត្តិការផ្ទាល់ រវាងស្ថាប័នពង្រឹងការអនុវត្តច្បាប់របស់ខ្លួន និងក្នុងករណីដែលមានកិច្ចព្រមព្រៀង ឬ ការចាត់ចែងបែបនេះរួចស្រេចហើយនោះ អាចធ្វើវិសោធនកម្មលិខិតូបករណ៍ទាំងនោះ។ ក្នុងករណីគ្មានកិច្ចព្រមព្រៀង ឬ ការចាត់ចែងបែបនោះរវាងភាគីពាក់ព័ន្ធនៅឡើយទេ ភាគីនានាអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការជាមួយគ្នាក្នុងការពង្រឹងការអនុវត្តច្បាប់ ដែលទាក់ទងនឹងបទល្មើសនានា ដូចមានចែងក្នុងអនុសញ្ញានេះ។ ក្នុងករណីសមស្រប ភាគីនានាត្រូវប្រើប្រាស់កិច្ចព្រមព្រៀងឬការចាត់ចែងនានាទាំងនោះឲ្យបានពេញលេញ ដែលរួមទាំងអង្គការអន្តរជាតិ ឬអង្គការថ្នាក់តំបន់ផងដែរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពង្រឹងការអនុវត្តច្បាប់របស់ខ្លួន។

៣. ភាគីនានាត្រូវប្រឹងប្រែងធ្វើសហប្រតិបត្តិការទៅតាមមធ្យោបាយដែលខ្លួនមាន ដើម្បីឆ្លើយតបនឹងអំពើជួញដូរមនុស្ស និងបទល្មើសដទៃទៀត ដូចមានចែងក្នុងអនុសញ្ញានេះ ដោយត្រូវមានការប្តេជ្ញាតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប។

## មាត្រា ២១
## កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការរឹបអូស

១. ភាគីណាមួយបានទទួលសំណើពីភាគីផ្សេងទៀត ដែលមានយុត្តាធិការលើបទល្មើស ដូចមានចែងក្នុងអនុសញ្ញានេះ សម្រាប់ការរឹបអូសផលពីឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ បរិក្ខារ ឬ សម្ភារៈផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១៧ វាក្យខ័ណ្ឌ ១ នៃអនុសញ្ញានេះ ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន ត្រូវអនុវត្តដូចខាងក្រោមនេះ ឲ្យបានច្រើនបំផុតតាមតែអាចធ្វើបាន នៅក្នុងក្រមខ័ណ្ឌនៃច្បាប់ជាតិ៖

ក. ដាក់ជូនសំណើទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីទទួលបានបទបញ្ជាសម្រាប់ការរឹបអូស និងក្នុងករណីដែលមានការផ្តល់បទបញ្ជាបែបនោះ ត្រូវអនុវត្តបទបញ្ជានោះឲ្យមានប្រសិទ្ធភាព ឬ

ខ. ដាក់ជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីការអនុវត្តដូចមានក្នុងសំណើ នូវបញ្ជានៃការរឹបអូសដែលចេញដោយតុលាការនៅក្នុងដែនដីនៃភាគីជាអ្នកស្នើសុំ អនុលោមតាមមាត្រា ១៧ វាក្យខ័ណ្ឌ ១ នៃអនុសញ្ញានេះ ពាក់ព័ន្ធនឹងផលពីឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ បរិក្ខារ ឬ សម្ភារៈផ្សេងទៀត ដែលស្ថិតនៅក្នុងដែនដីនៃភាគីដែលបានទទួលការស្នើសុំ ដូចចែងក្នុងមាត្រា ១៧ វាក្យខ័ណ្ឌ ១។

២. តាមសំណើធ្វើឡើងដោយភាគីមួយផ្សេងទៀត ដែលមានយុត្តាធិការលើបទល្មើសដូចមានចែងក្នុងអនុសញ្ញានេះ ភាគីជាអ្នកទទួលសំណើ ត្រូវចាត់វិធានការដើម្បីកំណត់អត្តសញ្ញាណ អង្កេតដាន និងបង្កក ឬ ឃាត់ទុកផលពីឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ បរិក្ខារ ឬ សម្ភារៈផ្សេងទៀត ដូចមានយោងក្នុងមាត្រា ១៧ វាក្យ

ខ័ណ្ឌ ១ នៃអនុសញ្ញានេះ សម្រាប់ការរឹបអូស ដែលនឹងត្រូវធ្វើតាមបញ្ជា ឬមួយដោយភាគីជាអ្នកស្នើសុំ ឬ អនុលោមតាមសំណើដូចមានក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះ ពីសំណាក់ភាគីជាអ្នកទទួលសំណើ។

៣. ប្រការនានាក្នុងមាត្រា១៨ នៃអនុសញ្ញានេះ មានសុពលភាពអនុវត្តចំពោះមាត្រានេះ តាមការចាំបាច់។ បន្ថែមលើព័ត៌មានដូចមានចែងក្នុងមាត្រា១៨ សំណើដែលធ្វើឡើងអនុលោមតាមមាត្រានេះ ត្រូវមានៈ

ក. សេចក្តីអធិប្បាយគ្រប់គ្រាន់អំពីទ្រព្យសម្បត្តិ ដែលត្រូវរឹបអូស និងសេចក្តីបញ្ជាក់អង្គហេតុដែលជាមូលដ្ឋានសម្រាប់ការស្នើសុំរបស់ភាគីជាអ្នកស្នើសុំ ដើម្បីអាចឲ្យភាគីជាអ្នកទទួលការស្នើសុំ ធ្វើការស្វែងរកដីកានៅក្រោមច្បាប់ក្នុងប្រទេសរបស់ខ្លួន ក្នុងករណីសំណើនោះទាក់ទងនឹងវាក្យខ័ណ្ឌ ១ (ក) នៃមាត្រានេះ។

ខ. ឯកសារចម្លងស្របច្បាប់ដែលអាចប្រើការបានមួយច្បាប់ នៃដីការឹបអូស ដែលជាមូលដ្ឋាននៃការចេញសំណើដែលធ្វើឡើងដោយភាគីជាអ្នកស្នើសុំ សេចក្តីបញ្ជាក់អង្គហេតុ និងព័ត៌មាន ទៅតាមវិសាលភាពនៃការអនុវត្តដីកាដែលបានស្នើសុំ ក្នុងករណីដែលសំណើនោះទាក់ទងនឹងវាក្យខ័ណ្ឌ ១ (ខ) នៃមាត្រានេះ ។

គ. សេចក្តីបញ្ជាក់អង្គហេតុ ដែលជាមូលដ្ឋាននៃសំណើរបស់ភាគីអ្នកស្នើសុំ និងសេចក្តីអធិប្បាយអំពីចំណាត់ការដែលស្នើឡើង ក្នុងករណីដែលសំណើនោះទាក់ទងនឹងវាក្យខ័ណ្ឌ ២ នៃមាត្រានេះ។

៤. សេចក្តីសម្រេច ឬ ចំណាត់ការនានា ដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះ ត្រូវតែបានទទួលការពិចារណាដោយភាគីអ្នកទទួលការស្នើសុំ អនុលោមតាម និងស្របជាមួយប្រការនានានៅក្នុងច្បាប់ជាតិនិង នីតិវិធីច្បាប់នៃភាគីនោះ រាល់សន្ធិសញ្ញាទ្វេភាគី ឬ ពហុភាគី កិច្ចព្រមព្រៀង ឬ ការចាត់ចែងដែលជាប់ជាកាតព្វកិច្ចពាក់ព័ន្ធជាមួយភាគីជាអ្នកស្នើសុំ និងសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញលើបញ្ហាព្រហ្មទណ្ឌ។

៥. ប្រសិនបើភាគីមួយសម្រេចចាត់វិធានការនានា ដូចមានយោងក្នុងវាក្យខ័ណ្ឌ ១ និង ២ នៃមាត្រានេះ ដោយដាក់លក្ខខណ្ឌ ដោយសារតែសន្ធិសញ្ញាពាក់ព័ន្ធណាមួយដែលមានស្រាប់ ភាគីនោះត្រូវចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានចាំបាច់ និងគ្រប់គ្រាន់សម្រាប់សន្ធិសញ្ញានោះ។

៦. ប្រការនានាក្នុងមាត្រានេះ នឹងពុំត្រូវបកស្រាយថាមានអានុភាពលើសិទ្ធិរបស់ភាគី ទីបីណាមួយឡើយ។

៧. ភាគីនានាត្រូវពិចារណាដាក់បញ្ចូលសន្ធិសញ្ញាទ្វេភាគី ឬពហុភាគី កិច្ចព្រមព្រៀង ឬ ការចាត់ចែងនានា ដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលធ្វើឡើងអនុលោមតាមមាត្រានេះ។

## មាត្រា ២២

### ការចាត់ចែងផលពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិដែលបានរឹបអូស

១. ផលពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិដែលបានរឹបអូសដោយភាគីណាមួយ អនុលោមតាមមាត្រា ១៧ ឬ មាត្រា ២១ វាក្យខណ្ឌ ១ នៃអនុសញ្ញានេះ ត្រូវចាត់ចែងដោយភាគីនោះ អនុលោមតាមច្បាប់ជាតិ និង នីតិវិធីរដ្ឋបាលរបស់ប្រទេសខ្លួន។

២. នៅពេលធ្វើចំណាត់ការតាមសំណើដែលធ្វើឡើងដោយភាគីដទៃណាមួយ អនុលោមតាមមាត្រា ២១ នៃអនុសញ្ញានេះ និងស្របតាមអំណាចនៃច្បាប់ជាតិ និងតាមសំណើរបស់ភាគីជាអ្នកស្នើសុំ ភាគីនានា ត្រូវចាត់ទុកជាអាទិភាពនូវការបញ្ជូនផលពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិដែលបានរឹបអូសនោះ មកភាគី ជាអ្នកស្នើសុំ ដើម្បីឲ្យភាគីនេះអាចផ្តល់ជាសំណង និងជំនួយឧបត្ថម្ភ ដល់ជនរងគ្រោះដោយសារការ ជួញដូរ ឬ បង្វិលផលពីឧក្រិដ្ឋកម្ម ឬ ទ្រព្យសម្បត្តិបែបនេះទៅម្ចាស់ស្របច្បាប់។

៣. នៅពេលធ្វើចំណាត់ការតាមសំណើធ្វើឡើងដោយភាគីមួយផ្សេងទៀត អនុលោមតាមមាត្រា ១៧ និង មាត្រា ២១ នៃអនុសញ្ញានេះ ភាគីណាមួយអាចធ្វើការគិតគូរជាពិសេស ដើម្បីធ្វើឲ្យមានកិច្ចព្រមព្រៀង ឬ ការចាត់ចែងនានាអំពីការចែករំលែកជាមួយភាគីដទៃទៀតជាទៀងទាត់ ឬ ទៅតាមករណីដាច់ដោយ ឡែកពីគ្នា នូវផលពីឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិបែបនោះ ឬ មូលនិធិដែលបានពីការលក់ផលពីឧក្រិដ្ឋ កម្ម ឬ ទ្រព្យសម្បត្តិបែបនោះ អនុលោមតាមច្បាប់ ឬ នីតិវិធីរដ្ឋបាលរបស់ប្រទេសនៃភាគីនោះ។

# ជំពូក ៧
# អវសានបញ្ញត្តិ

## មាត្រា ២៣
## ការបង្កើតរចនាសម្ព័ន្ធសម្របសម្រួល

ភាគីនីមួយៗត្រូវពិចារណាបង្កើតរចនាសម្ព័ន្ធសម្របសម្រួល នៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ មនុស្ស ដែលរួមទាំង ការពង្រីកកិច្ចសហប្រតិបត្តិការក្នុងគ្រប់វិស័យទាំងអស់នៃអនុសញ្ញានេះ។

## មាត្រា ២៤
## ការតាមដាន ការពិនិត្យ និងការរាយការណ៍

១. កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) មានភារៈទទួលខុសត្រូវជំរុញ តាម ដាន ការពិនិត្យ និងការរាយការណ៍ជាទៀងទាត់មកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (AMMTC) ស្តីពីការអនុវត្តអនុសញ្ញានេះឲ្យមានប្រសិទ្ធភាព។

២. លេខាធិការដ្ឋានអាស៊ាន ត្រូវផ្តល់ការគាំទ្រដល់ការដឹកនាំ និងការសម្របសម្រួលលើការអនុវត្តអនុសញ្ញានេះ និងជួយ SOMTC លើគ្រប់កិច្ចការដែលទាក់ទងនឹងអនុសញ្ញានេះ។

## មាត្រា ២៥
## ការសម្ងាត់នៃឯកសារ កំណត់ត្រា និងព័ត៌មាន

១. ភាគីនីមួយៗត្រូវរក្សាអាថ៌កំបាំង និងការសម្ងាត់នៃឯកសារ កំណត់ត្រា និងព័ត៌មានដទៃទៀត ដែលទទួលបានពីភាគីមួយផ្សេងទៀត ដែលរួមទាំងប្រភពនៃឯកសារ កំណត់ត្រានិងព័ត៌មានទាំងនោះផងដែរ។

២. គ្មានឯកសារ កំណត់ត្រា ឬ ព័ត៌មានដទៃណាមួយដែលទទួលបាន អនុលោមតាមអនុសញ្ញានេះ នឹងត្រូវបើកចំហឬ ចែករំលែកជាមួយភាគី រដ្ឋ ឬ បុគ្គលណាមួយផ្សេងទៀតឡើយ លើកលែងតែមានការព្រមព្រៀងជាមុនពីភាគី ដែលបានផ្តល់ឯកសារ កំណត់ត្រា ឬ ព័ត៌មាននោះ។

## មាត្រា ២៦
## ទំនាក់ទំនងជាមួយលិខិតូបករណ៍អន្តរជាតិដទៃទៀត

អនុសញ្ញានេះនឹងមិនមានឥទ្ធិពលលើកាតព្វកិច្ចនានារវាងភាគីនានា អនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ឬ ក្នុងករណីដែលភាគីទាំងនេះឯកភាព អនុសញ្ញានេះនឹងមិនរារាំងភាគីទាំងនេះពីការផ្តល់ជំនួយដល់គ្នាទៅវិញទៅមក អនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ឬ ប្រការនានាដែលមានចែងក្នុងច្បាប់ជាតិរបស់ភាគីទាំងនោះឡើយ។

## មាត្រា ២៧
## ការដោះស្រាយទំនាស់

រាល់ភាពមិនចុះសម្រុងគ្នា ឬ ទំនាស់រវាងភាគីនានា ដែលកើតចេញពីការបកស្រាយ ឬ ការអនុវត្តប្រការនានានៃអនុសញ្ញានេះ ត្រូវតែបានដោះស្រាយជាមិត្តភាព តាមរយៈការពិគ្រោះយោបល់ និងការចរចា រវាងភាគីទាំងនោះ តាមមធ្យោបាយការទូត ឬ មធ្យោបាយសន្តិវិធីដទៃទៀតណាមួយសម្រាប់ការដោះស្រាយទំនាស់ ទៅតាមការឯកភាពរវាងភាគីទាំងនោះ។

## មាត្រា ២៨
## ការផ្តល់សច្ចាប័ន ការយល់ព្រម និងកន្លែងតំកល់ឯកសារ

១. អនុសញ្ញានេះត្រូវតែផ្តល់សច្ចាប័ន ឬការយល់ព្រម ស្របតាមនីតិវិធីផ្ទៃក្នុងនៃភាគីទាំងនេះ។

២. លិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ឬ ការយល់ព្រម ត្រូវតែតំកល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលត្រូវជូនដំណឹងជាបន្ទាន់មកភាគីដទៃទៀតអំពីការតំកល់ឯកសារទាំងនោះ។

## មាត្រា ២៩
## ការចូលជាធរមាន និងវិសោធនកម្ម

ក. អនុសញ្ញានេះត្រូវចូលជាធរមាន នៅរយៈពេលសាមសិប(៣០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍ទីប្រាំមួយ(៦) នៃសច្ចាប័ន ឬ ការយល់ព្រម នៅអគ្គលេខាធិការអាស៊ាន ទាក់ទងនឹងភាគីនានាដែលបានដាក់ជូនលិខិតូបករណ៍នៃសច្ចាប័ន ឬ ការយល់ព្រមរបស់ខ្លួន។

ខ. ចំពោះភាគីណាមួយដែលផ្ដល់សច្ចាប័ន ឬ យល់ព្រមតាមអនុសញ្ញានេះ នៅក្រោយការតំកល់លិខិតូបករណ៍ទីប្រាំមួយនៃសច្ចាប័ន ឬ ការយល់ព្រម ប៉ុន្តែនៅមុនថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន អនុសញ្ញានេះក៏ត្រូវអនុវត្តចំពោះភាគីនោះនៅកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានផងដែរ។ ទាក់ទងនឹងភាគីដែលផ្ដល់សច្ចាប័ន ឬ យល់ព្រមនឹងអនុសញ្ញានេះនៅក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ អនុលោមតាមវាក្យខ័ណ្ឌ១ អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់ភាគីនោះនៅកាលបរិច្ឆេទដែលលិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ឬ ការយល់ព្រមរបស់ភាគីនោះត្រូវបានដាក់តំកល់។

គ. អនុសញ្ញានេះអាចនឹងកែប្រែ ឬ ធ្វើវិសោធនកម្មនៅក្នុងពេលណាមួយ ដោយការព្រមព្រៀងគ្នាជាលាយលក្ខអក្សរពីភាគីទាំងនេះ។ ការកែប្រែ ឬ វិសោធនកម្មបែបនោះ នឹងត្រូវចូលជាធរមាន នៅកាលបរិច្ឆេទដែលមានការព្រមព្រៀងគ្នាដោយភាគីទាំងនេះ និងត្រូវក្លាយជាផ្នែកមួយនៃអនុសញ្ញានេះ។

ឃ. រាល់ការកែប្រែ ឬ វិសោធនកម្ម មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងនេះ ដោយសារតែ ឬ ដោយផ្អែកលើប្រការនានានៃអនុសញ្ញានេះ នៅមុនការចូលជាធរមាននៃការកែប្រែ ឬ វិសោធនកម្មនោះឡើយ។

## មាត្រា ៣០
## ការដកខ្លួន

១. ភាគីណាមួយអាចដកខ្លួនចេញពីអនុសញ្ញានេះនៅពេលណាមួយក៏បាន ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះសម្រាប់ភាគីនោះ។

២. ការដកខ្លួនត្រូវតែបានជូនដំណឹងជាលិខិតូបករណ៍នៃការដកខ្លួនទៅអគ្គលេខាធិការអាស៊ាន។

៣. ការដកខ្លួនត្រូវចូលជាធរមាននៅរយៈពេលមួយរយប៉ែតសិប(១៨០)ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ានបានទទួលលិខិតូបករណ៍នៃការសុំដកខ្លួននោះ។

៤. អគ្គលេខាធិការអាស៊ាន ត្រូវជូនដំណឹងជាបន្ទាន់មកភាគីផ្សេងទៀតទាំងអស់អំពីរាល់ការដកខ្លួន។

**មាត្រា ៣១**

**ការចុះបញ្ជី**

អនុសញ្ញានេះត្រូវចុះបញ្ជីដោយអគ្គលេខាធិការអាស៊ាន នៅលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ដោយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញសហប្រជាជាតិ។

ធ្វើនៅកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទីម្ភៃមួយ ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់ប្រាំ ជាអត្ថបទដើមតែមួយច្បាប់ជាភាសាអង់គ្លេស។

**សម្រាប់ ប្រ៊ុយណេ ដារូសាឡាមៈ**

ហាជី ហាសាណាល បូលគីយ៉ា

ស៊ុលតង់នៃប្រទេសប្រ៊ុយណេ ដារូសាឡាម

**សម្រាប់ព្រះរាជាណាចក្រកម្ពុជាៈ**

សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី

**សម្រាប់សាធារណរដ្ឋឥណ្ឌូនេស៊ីៈ**

ចូកូ វីឌូឌូ

ប្រធានាធិបតី

**សម្រាប់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវៈ**

ថុងស៊ីង ថាមម៉ាវង់

នាយករដ្ឋមន្ត្រី

**សម្រាប់ប្រទេសម៉ាឡេស៊ីៈ**

ដាតូ ស្រ៊ី ម៉ូណាជីប អាប់ឌុល រ៉ៃហ្សាក់

នាយករដ្ឋមន្រ្តី

**សម្រាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ាៈ**

ថេន សេន

ប្រធានាធិបតី

**សម្រាប់សាធារណរដ្ឋហ្វីលីពីនៈ**

បេនិកណូ អេស អាគីណូ III

នាយករដ្ឋមន្រ្តី

**សម្រាប់សាធារណរដ្ឋសឹង្ហបុរីៈ**

លី ហៀន លុង

នាយករដ្ឋមន្រ្តី

**សម្រាប់ព្រះរាជាណាចក្រថៃៈ**

ឧត្តមសេនីយ៍ ប្រាយុទ ចាន់ អូ ចា ( RET. )

នាយករដ្ឋមន្ត្រី

**សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម៖**

ង្វៀន ថាន់ឌុង
នាយករដ្ឋមន្ត្រី